ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.............................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧
# និងទិសដៅការងារឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ខែត្រកំពង់ចាម ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨

ឲឲឲ✵ៜៜៜ

សូមគោរព៖

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧និងទិសដៅការងារឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា។ សន្និបាតរបស់យើងត្រូវបានធ្វើឡើងក្នុងគោលបំណងអបអរសាទរ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆ្នាំ២០១៧ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៨ ដើម្បីឈានទៅសម្រេចឱ្យបាននូវជោគជ័យថ្មីៗបន្ថែមទៀត។ ការរៀបចំសន្និបាតនេះឡើង ក៏ដើម្បីផ្តល់ឱកាស និងបង្កលក្ខណៈឱ្យមន្ត្រីយើងទាំងស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្រ បានជួបជុំគ្នាក្រោមបរិយាកាសរីករាយ សំដៅបង្កើនស្មារតីសហការគ្នា សាមគ្គីភាព និងភាតរភាព ក្នុងនាមជាសមាជិកគ្រួសារធនាគារជាតិនៃកម្ពុជាតែមួយ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលក្នុងនោះក៏មានក្រុមសេដ្ឋវិទូវ័យក្មេងនិងមន្ត្រីវ័យក្មេងផងដែរ។

នាឆ្នាំនេះ យើងបានជ្រើសរើសយកខេត្តកំពង់ចាមមកប្រារព្ធកម្មវិធីសន្និបាតសារជាថ្មី ដើម្បីផ្លាស់ប្តូរបរិយាកាសនិងអនុញ្ញាតឱ្យសមាជិកសមាជិកា ជាពិសេសយុវជនយើងបានស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជាពាក់ព័ន្ធនឹងខេត្តកំពង់ចាម ព្រមទាំងសក្តានុពលនិងការរីកចម្រើនរបស់ខេត្ត។ ខេត្តកំពង់ចាមសម្បូរដោយសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់របស់កម្ពុជា រួមមាន៖ i/- ប្រាសាទហាន់ជ័យ មានទីតាំងស្ថិតនៅឃុំហាន់ជ័យ ស្រុកកំពង់សៀម កសាងឡើងដោយព្រះបាទភវវរ្ម័នទី១ ដែលបានបង្រួបបង្រួមទឹកដីនាសម័យចេនឡា និងបានដាក់ឈ្មោះប្រទេសយើងថា "កម្ពុជា" ii/- ប្រាសាទវត្តនគរ ជាប្រាសាទបែបពុទ្ធសាសនា ខុសប្លែកពីប្រាសាទដទៃដែលគោរពតាមសាសនាព្រាហ្មណ៍ ហើយត្រូវបានកសាងឡើងដោយព្រះបាទជ័យវរ្ម័នទី៧ ក្នុងសម័យអង្គរដ៏រុងរឿង iii/- ខេត្តកំពង់ចាមក៏ជាអតីតរាជធានីកម្ពុជា ក្នុងរជ្ជកាលព្រះស្រីជេដ្ឋា ហៅស្តេចកន ដែលទ្រង់បានដាក់ឈ្មោះរាជធានីនេះថា "ក្រុងស្រឡប់ពិជ័យព្រៃនគរ"។ ព្រះអង្គក៏ជាព្រះរាជាទីមួយដែលមានទស្សនវិស័យវែងឆ្ងាយ ដោយបានបោះពុម្ពរូបិយវត្ថុជាតិ "ប្រាក់ស្លឹង" ដែលមានរូបនាគសម្រាប់ជាមធ្យោបាយដោះដូរពាណិជ្ជកម្ម និងបានរៀបចំប្រព័ន្ធពន្ធដារ ព្រមទាំងបើកទូលាយពាណិជ្ជកម្មជាមួយបរទេស ដូចជា ជនជាតិអេស្ប៉ាញ ព័រទុយហ្គាល់ និងចិនជាដើម។ ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចនិងពង្រីកឫទ្ធានុភាពប្រទេសកម្ពុជាទៀតផង។ គួររំលេចថា ខេត្តកំពង់ចាមមានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងសមិទ្ធផលរូបវ័ន្ត និងភាពប្រសើរឡើងនៃជីវភាពរស់នៅរបស់ប្រជាជន។ ប្រព័ន្ធធនាគារបានដើរតួនាទីដ៏សំខាន់ក្នុងការរួមចំណែកជំរុញការអភិវឌ្ឍទាំងនេះ។ ជាក់ស្តែង ចំនួនគ្រឹះស្ថានធនាគារពាណិជ្ជបានកើនឡើងដល់ ១៦សាខា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកើនដល់ ១៣សាខា ដែលកំពុងធ្វើប្រតិបត្តិការនៅខេត្តកំពង់ចាម។

សន្និបាតរបស់យើងថ្ងៃនេះ ក៏ធ្វើឡើងដើម្បីចូលរួមជាមួយនឹងប្រជាពលរដ្ឋទូទាំងប្រទេស អបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ នៃទិវាជ័យជម្នះ ៧មករា (៧ មករា ១៩៧៩ - ៧ មករា ២០១៨) ដែលនឹងឈានមកដល់នាពេលខាងមុខ។ ប្រជាជនកម្ពុជាទាំងអស់ត្រូវ

បានរំដោះឱ្យរួចផុតពីការកាប់សម្លាប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត នាថ្ងៃ៧ ខែមករា ឆ្នាំ ១៩៧៩ និងបាននាំមកវិញនូវសិទ្ធិសេរីភាពនិងវឌ្ឍនភាពរហូតដល់សព្វថ្ងៃ ដែលយើងទាំងអស់គ្នាត្រូវចូលរួមសាមគ្គីថែរក្សាសមិទ្ធផលដ៏ថ្លៃថ្លានេះឱ្យបានគង់វង្ស។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ក្នុងឱកាសដ៏ឱឡារិកនេះ ខ្ញុំសូមជម្រាបជូនអង្គសន្និបាតពីស្ថានភាពសេដ្ឋកិច្ចពិភពលោក តំបន់ និងកម្ពុជា ព្រមទាំងការរួមចំណែករបស់ធនាគារជាតិនៃកម្ពុជាក្នុងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចនៅឆ្នាំ២០១៧នេះ ដូចតទៅ៖

**I/- ស្ថានភាពសេដ្ឋកិច្ចពិភពលោក តំបន់ និងកម្ពុជា**

សេដ្ឋកិច្ចពិភពលោកនិងតំបន់នាឆ្នាំ២០១៧ បានបន្តរីកចម្រើនល្អប្រសើរ ដែលគាំទ្រដោយកំណើនសេដ្ឋកិច្ចនៅប្រទេសអភិវឌ្ឍន៍ ដូចជា សហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន ក្នុងពេលដែលកំណើនសេដ្ឋកិច្ចចិនបានងើបឡើងបន្តិចមកវិញ បន្ទាប់ពីបានថមថយក្នុងរយៈពេល៥ឆ្នាំកន្លងទៅ។ នៅតំបន់អាស៊ាន សេដ្ឋកិច្ចបន្តរក្សាល្បឿនកំណើនខ្ពស់ធៀបនឹងតំបន់ដទៃលើពិភពលោក ដោយសារភាពរឹងមាំនៃតម្រូវការក្នុងស្រុក លំហូរមូលធន និងកំណើនតម្រូវការខាងក្រៅ។ ស្ថិតក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជានាឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានថាបន្តកើនឡើងក្នុងអត្រា ៦,៩% ដែលគាំទ្រដោយកំណើនក្នុងវិស័យកាត់ដេរ សំណង់ និងទេសចរណ៍។

ជារួម សមិទ្ធផលដែលបន្តសម្រេចបានខាងលើអាស្រ័យលើកត្តាចម្បង ៣ គឺ៖ i/- សន្តិភាពនិងស្ថិរភាពនយោបាយ ii/- គោលនយោបាយទាក់ទាញការវិនិយោគនិងទេសចរណ៍ និង iii/- ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ សន្តិភាពនៅទូទាំងប្រទេសនិងស្ថិរភាពនយោបាយចាប់តាំងពីឆ្នាំ១៩៩៨មក គឺជាមូលដ្ឋានយ៉ាងរឹងមាំសម្រាប់ការអភិវឌ្ឍ ដោយសារការពង្រឹងបានជំនឿទុកចិត្តនិងសុទិដ្ឋិនិយមពីសំណាក់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេស និងភ្ញៀវទេសចរ មកលើការអភិវឌ្ឍនិងសុវត្ថិភាពនៅកម្ពុជា។

## II/- ការរួមចំណែករបស់ធនាគារជាតិនៃកម្ពុជាក្នុងការគាំទ្រការអភិវឌ្ឍនិងកំណើន

នាឆ្នាំ២០១៧នេះ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច ដោយសម្រេចបាននូវលទ្ធផលវិជ្ជមានចម្បងៗដូចខាងក្រោមៈ

**១. ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចៈ** គោលនយោបាយរូបិយវត្ថុត្រូវបានអនុវត្តប្រកបដោយភាពប្រុងប្រយ័ត្ន បត់បែន និងមានសង្គតិភាពជាមួយគោលនយោបាយសារពើពន្ធ ហើយបានរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងរឹងមាំ។ អត្រាប្តូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាពក្នុងរង្វង់ ៤.០៥០ រៀល ក្នុងមួយដុល្លារអាមេរិក តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ផ្អែកតាមតម្រូវការនិងមូលដ្ឋានសេដ្ឋកិច្ច។ ស្ថិរភាពអត្រាប្តូរប្រាក់គួបផ្សំនឹងការផ្គត់ផ្គង់រូបិយវត្ថុក្នុងកម្រិតសមស្របបានរួមចំណែកយ៉ាងសំខាន់ ក្នុងការរក្សាស្ថិរភាពថ្លៃ។ ជាក់ស្តែង អត្រាអតិផរណាជាមធ្យមនៅឆ្នាំ២០១៧ មានកម្រិតទាបអាចគ្រប់គ្រងបានប្រមាណ ២,៩% ប្រហាក់ប្រហែលនឹងអត្រាមធ្យមក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (២,៨%) ដែលបង្ហាញពីការបន្តសម្រេចបានការរក្សាស្ថិរភាពថ្លៃបានយ៉ាងល្អប្រសើរ។ ស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់បានការពារអំណាចទិញរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលមានចំណូលទាប និងពង្រឹងជំនឿទុកចិត្តសាធារណជនមកលើរូបិយវត្ថុជាតិ។

**២. ការអភិវឌ្ឍវិស័យធនាគារនិងការរក្សាស្ថិរភាពហិរញ្ញវត្ថុៈ** នៅឆ្នាំ២០១៧ គោលដៅចម្បងក្នុងការអភិវឌ្ឍវិស័យធនាគារ គឺការបន្តពង្រឹងតុល្យភាពរវាងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនិងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ម៉្យាងដើម្បីបន្តរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចចម្បងៗ ដែលបានបោះជំហានទៅមុខឥតឈប់ឈរនិងមានតម្រូវការធនធានហិរញ្ញវត្ថុ និងម៉្យាងទៀតដើម្បីពង្រឹងស្ថិរភាពនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ដែលជាបរិស្ថានរក្សានិរន្តរភាពនៃកំណើនសេដ្ឋកិច្ច។ នេះគឺជាបញ្ហាប្រឈមដ៏ស្រួចស្រាល់មួយ ដែលប្រទេសនានាលើពិភពលោកនិងតំបន់ កំពុងជម្នះផងដែរ ជាពិសេសក្នុងប្រទេសកំពុងលូតលាស់និងប្រទេសកំពុងអភិវឌ្ឍន៍។ ជាលទ្ធផល ប្រព័ន្ធធនាគារនៅកម្ពុជាសម្រេចបាន

គោលដៅទាំងពីរខាងលើគួរជាទីមោទនៈ។ ការបែងចែកធនធានហិរញ្ញវត្ថុត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្នទៅតាមតម្រូវការទីផ្សារ ដោយបានជៀសផុតពីការគរពូនជ្រុលនៃឥណទានទៅកាន់វិស័យណាមួយ ជាពិសេសចំពោះវិស័យមិនមែនផលិតកម្ម។ ឥណទានទៅកាន់វិស័យឯកជនបានបន្ថយល្បឿនកំណើនមកត្រឹមកម្រិតសមស្រប ទន្ទឹមនឹងការបង្កើនដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាលំដាប់ ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ។ ប្រព័ន្ធធនាគារក៏ត្រូវបានពង្រឹងភាពធន់នឹងហានិភ័យសន្ទនីយភាព ដោយបានបង្កើនគុណភាពនិងកម្រិតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទៅតាមដំណាក់កាលជាមួយនឹងការពង្រឹងយន្តការគ្រប់គ្រងសន្ទនីយភាព អនុលោមតាមគោលការណ៍បាសែល III ដែលមានលក្ខណៈប្រុងប្រយ័ត្នខ្ពស់។ ម៉្យាងទៀត គោលការណ៍តម្លាភាព ការប្រកួតប្រជែងដោយសមភាព និងកិច្ចការពារអតិថិជន ក៏ត្រូវបានលើកកម្ពស់ផងដែរ តាមរយៈការត្រួតពិនិត្យ និងតាមដានលើការអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តពិដានអត្រាការប្រាក់ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងឥណទានជនបទ ក្នុងអត្រា ១៨% ដែលបានបង្កលក្ខណៈអំណោយផលដល់ប្រជាកសិករ និងសហគ្រាសធុនតូចនិងមធ្យម ឱ្យទទួលបានហិរញ្ញប្បទានក្នុងតម្លៃទាបជាងមុន សម្រាប់បង្កើនសកម្មភាពអាជីវកម្ម។ អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា ក្នុងគោលបំណងពង្រឹងនិរន្តរភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបំបាត់ការឃោសនាកេងប្រវ័ញ្ចនិងបោកប្រាស់ប្រជាពលរដ្ឋ ពីសំណាក់ជនឆ្លៀតឱកាសមួយចំនួន ធនាគារជាតិនៃកម្ពុជាបានបង្កើនការយល់ដឹងរបស់សាធារណជនលើកម្មសិទ្ធិភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ជារបស់ឯកជន មិនមែនជារបស់រដ្ឋ ប្រកបដោយជោគជ័យ តាមរយៈការផ្សព្វផ្សាយដល់សាធារណជន ការប្តូរនិមិត្តសញ្ញា និងកិច្ចសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីពង្រីកការផ្សព្វផ្សាយ

ឱ្យកាន់តែទូលំទូលាយ។ ដូច្នេះ ដើម្បីជៀសវាងការបោកបញ្ឆោត និងរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងលើកកម្ពស់ការយល់ដឹងពីសេវាហិរញ្ញវត្ថុរបស់សាធារណជននិងអាជ្ញាធរមូលដ្ឋានជាបន្តបន្ទាប់ តាមរយៈការចុះពន្យល់តាមមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ បណ្តាញសង្គម និងការដាក់ឱ្យប្រើប្រាស់នូវទូរស័ព្ទដែលសម្រាប់ជូនដំណឹងមកធនាគារជាតិនៃកម្ពុជាពីបញ្ហានានាដែលកើតឡើង ពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់អតិថិជន។ សម្រាប់រយៈកាលវែង ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាក៏កំពុងបញ្ចប់ការរៀបចំយុទ្ធសាស្ត្រ ស្តីពីបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់កម្ពុជា ដែលនឹងក្លាយជាផែនទីមគ្គុទ្ទេសក៍សម្រាប់ការបង្កើនបរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយចីរភាព។

ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងអស់ខាងលើ នៅឆ្នាំ២០១៧ វិស័យធនាគារបានបម្រើសេវាហិរញ្ញវត្ថុដល់ប្រជាជនពេញវ័យបន្ថែមប្រមាណ ៦០ ម៉ឺននាក់ ដែលធ្វើឱ្យអត្រាបរិយាប័ន្នហិរញ្ញវត្ថុកើនដល់ ៥៦% ស្មើនឹងចំនួនប្រជាជនពេញវ័យប្រមាណ ៦,២ លាននាក់។ កំណើនបរិយាប័ន្នហិរញ្ញវត្ថុសម្រេចបានក្នុងបរិការណ៍ដែលការទទួលបានសេវាហិរញ្ញវត្ថុមានភាពកាន់តែងាយស្រួល ដូចដែលរបាយការណ៍នៃការធ្វើធុរកិច្ចឆ្នាំ២០១៧ របស់ធនាគារពិភពលោកបានផ្តល់ចំណាត់ថ្នាក់ទី៧ដល់កម្ពុជា ជាប្រទេសដែលមានភាពងាយស្រួលជាងគេលើពិភពលោកក្នុងការទទួលបានហិរញ្ញប្បទាន។ លើសពីនេះ ដើម្បីលើកកម្ពស់យេនឌ័រ ធនាគារជាតិនៃកម្ពុជា ប្តេជ្ញាបន្តកាត់បន្ថយនូវអត្រាស្ត្រីដែលមិនទាន់ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ពី ២៧% ក្នុងចំណោមស្ត្រីសរុប មក ១៣% នាឆ្នាំ២០២៥។

### ៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

ប្រព័ន្ធទូទាត់ជាផ្នែកមួយដ៏សំខាន់នៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ហើយប្រៀបដូចជាសរសៃឈាមនៃវិស័យហិរញ្ញវត្ថុ ដោយសារតួនាទីដ៏មានសារៈសំខាន់ចំពោះប្រតិបត្តិការសេដ្ឋកិច្ច។ រាល់ការធ្វើប្រតិបត្តិការពាណិជ្ជកម្មគ្រប់ជាន់ថ្នាក់ តាំងពីអាជីវកម្មខ្នាតតូច

រហូតដល់ធំៗ ទាមទារនូវការប្រើប្រាស់ការទូទាត់។ ដូច្នេះ ការធ្វើឱ្យប្រព័ន្ធទូទាត់មានដំណើរការប្រកបដោយសុវត្ថិភាព ឆាប់រហ័ស និងចំណាយតិច នឹងរួមចំណែកជំរុញឱ្យសកម្មភាពសេដ្ឋកិច្ចប្រព្រឹត្តទៅដោយប្រសិទ្ធភាពផងដែរ និងរក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យបានរឹងមាំ។ ក្នុងគោលដៅនេះ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ ដោយផ្អែកលើបច្ចេកវិទ្យាទំនើប ដូចជា ការពង្រឹងសេវាទូទាត់រហ័ស (Fast Payment) ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ Cambodian Shared Switch (CSS) ព្រមទាំងកំពុងសិក្សាបង្កើតប្រព័ន្ធទូទាត់ដុលភ្លាមៗ (Real Time Gross Settlement-RTGS)។

ម៉្យាងទៀត ការផ្តល់សេវាធនាគារកណ្តាលដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ ដោយបានរៀបចំឱ្យមានប្រព័ន្ធអនឡាញ ដើម្បីសម្រួលដល់ការពិនិត្យមើលសមតុល្យក្នុងគណនីបានភ្លាមៗ ធ្វើការផ្ទេរប្រាក់ និងទូទាត់នានាប្រកបដោយប្រសិទ្ធភាព។ ធនាគារជាតិនៃកម្ពុជាក៏បានត្រៀមលក្ខណៈរួចជាស្រេច ដើម្បីផ្តល់សេវាធនាគារកណ្តាលពេញលេញផងដែរជូនដល់បណ្តាក្រសួង-ស្ថាប័ន សំដៅរួមចំណែកក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

ចំពោះព័ត៌មានឥណទាន បន្ទាប់ពីទទួលបានជោគជ័យលើការចែករំលែកព័ត៌មានឥណទានបុគ្គល ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជាគ្រោងនឹងដាក់ឱ្យដំណើរការនូវការចែករំលែកព័ត៌មានឥណទានរបស់ក្រុមហ៊ុនសាជីវកម្មនានា។ ការចែករំលែកព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយនឹងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាចគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាព។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមជម្រាបផងដែរថា កន្លងមកមានការលេចឮអំពីបញ្ហាការប្រើប្រាស់រូបិយប័ណ្ណ Crypto Currencies នៅកម្ពុជា។ ធនាគារជាតិនៃកម្ពុជាក៏បានចេញសេចក្តីជូនដំណឹងចំពោះការទប់ស្កាត់ការប្រើប្រាស់ ចរាចរ ទិញ លក់ ទូទាត់ និងផ្សព្វផ្សាយរូបិយវត្ថុ Crypto Currencies ដោយហេតុថា Crypto Currencies ជា

ឧបករណ៍ថ្មីមិនមានការគ្រប់គ្រងច្បាស់លាស់ ដូច្នេះអាចនាំមកនូវហានិភ័យខ្ពស់ចំពោះអ្នកប្រើប្រាស់ និងអាចជាមធ្យោបាយមួយក្នុងការសម្អាតប្រាក់។

**៤. អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

ឆ្លើយតបនឹងការរីកចម្រើនវិស័យធនាគារ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានពង្រឹងសមត្ថភាពធនធានមនុស្សជាលំដាប់ និងបានបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ននិងភាគីពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីបង្ការនិងទប់ស្កាត់ប្រតិបត្តិការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព។

ក្រៅពីនេះ ខ្ញុំក៏សូមជម្រាបជូនអង្គសន្និបាតយើងឱ្យបានជ្រាបផងដែរថា សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា នឹងត្រូវសម្ពោធបើកដំណើរការជាផ្លូវការនាដើមឆ្នាំ២០១៨នេះ។ សារមន្ទីរនេះហៅកាត់ថា ស.ស.រ ដែលមានឈ្មោះពេញថា សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន ត្រូវបានសាងសង់តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ។ សារមន្ទីរ ស.ស.រ ត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្ហាញពីប្រវត្តិនៃការរីកចម្រើនប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងតួនាទីធនាគារកណ្តាលនិងរូបិយវត្ថុ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា ចាប់តាំងពីសម័យហ្វូណនរហូតដល់បច្ចុប្បន្ន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ដើម្បីជ្រាបពីលទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារសំខាន់ៗ ខ្ញុំសូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតនាពេលបន្តិចទៀតនេះ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញមុខ

ងារ-ភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបានសមិទ្ធផលដ៏ប្រសើរជាបន្តបន្ទាប់នារយៈពេលកន្លងមក។ ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះគ្រប់ក្រសួង-ស្ថាប័ននានា នៅក្នុងវិស័យសាធារណៈនិងឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានបន្តគាំទ្រនិងរួមចំណែកនៅក្នុងសមិទ្ធផលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង នាងកញ្ញា ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងផ្លែផ្កា។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។**

**សូមអរគុណ**!